**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្រុមការងារអន្តរក្រសួង**

**ដើម្បីគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ**

# សេចក្តីជូនដំណឹង

ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងដាក់ឱ្យអនុវត្តប្រកាសលេខ ១២២២ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុនៅដំណាច់ខែ មករា ឆ្នាំ ២០១០ ខាងមុខនេះ ។ ដូច្នេះបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ត្រូវរៀបចំខ្លួនឱ្យបានរួចរាល់ដើម្បីសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មអភិវឌ្ឍអចលនវត្ថុ (សាងសង់ផ្ទះលក់- ជួល)ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ ត្រូវរួសរាន់មកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ដែលមានទីតាំងនៅការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគារថ្មីជាន់ទី ៣ ចាប់ពីដើមខែ កុម្ភៈ ឆ្នាំ ២០១០ ខាងមុខនេះតទៅ ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ ០១២ ៤៣០ ០០៩ / ០១៦ ៤៣០ ០០៨/ ០១១ ៨៦៨ ៩៦១ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩*

**អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ**

ឌី_តាឃី